# កេរ្តិ៍ឈ្មោះអង្គរវត្ត

## *THE REPUTE OF ANGKOR WAT*

*ដោយ* **ព្រះភិក្ខុវោទានោ ស. សុភ័ណ***

អង្គរវត្តជាអច្ឆរិយវត្ថុរបស់ពិភពលោកដែលបុព្វបុរសខ្មែរបន្សល់ទុកអោយយើងទាំងអស់គ្នា ។ កេរដំណែលដែលមិនអាចកាត់ថ្លៃបាននេះបានក្លាយទៅជាព្រលឹងជាតិខ្មែរ ដោយជនជាតិខ្មែរគ្រប់យុគគ្រប់សម័យរមែងលំអោនកាយវាចា ចិត្តចូលមកគោរពសក្ការបូជាបន្តរក្សាការពារនូវមរតកនេះតរៀងរហូតមក តាំងតែពីបុរាណកាលរាប់ពាន់ឆ្នាំកន្លងទៅហើយ ។ ពិតណាស់ទឹកដីខ្មែរដែលសំបូរទៅដោយធនធានធម្មជាតិ បណ្តាលអោយរីកដុះដាលធនធានវប្បធម៌គ្របដណ្តប់នៅលើថ្នាលខៀវខ្ចីស្រស់បំព្រងជារៀងដរាបឥតមានថ្ងៃណាស្វិតស្រពោនឡើយ ។ នេះហើយគឺមហានគរ នេះហើយគឺមហារាជវង្គពណ៌បង្កប់នៅក្នុងក្រអៅបេះដូងខ្មែរគ្រប់សម័យកាល ។

ក្នុងប្រទេសខ្មែរយើងមានប្រាសាទបុរាណជាច្រើនទាំងតូចទាំងធំពង្រាយពាសពេញ ព្រមទាំងមានសល់ច្រើនមីរដេរដាសក្នុងបណ្តាប្រទេសជិតខាងដូចជាប្រទេសថៃ លាវនិងវៀតណាម ។ តែក្នុងចំណោមប្រាសាទបុរាណទាំងនោះ យើងមានប្រាសាទអង្គរវត្តដែលមានទំហំធំស្កឹមស្កៃ លាតសន្ធឹងលើក្រលាផ្ទៃធំទូលាយនៃនគរយសោធរបុរៈ ។ អង្គរវត្តជាប់លេខមួយនៅលើពិភពលោកខាងស្ថាបត្យកម្មនិងក្បាច់ក្បូរចំលាក់នៅលើថ្មដា ។ ការតុបតែងប្រកបដោយមហិទ្ធិរិទ្ធខ្ពស់ខាងជាងសំណង់ ភាពរឹងប៉ឹងនៃថ្មភក់ដែលប្រកបដោយគុណភាពពិសេស ទំហំដ៏ធំស្កឹមស្កៃប្រកបដោយក្បាច់ក្បូររចនាដ៏មានជីវិតរស់រវើក ធ្វើឱ្យអង្គរវត្តឈរបង្ហាញរាងយ៉ាងសង្ហារនៅក្រោមស្បៃពណ៌សនៃពិភពចក្រវាឡ ធ្វើឱ្យអ្នកផងដែលមកឃើញលាន់មាត់សរសើរមិនដាច់ ដែលនៅក្នុងនោះមានទាំងជនជាតិខ្មែរយើងផ្ទាល់និងជនជាតិបរទេសផងដែរ ។

ក្នុងការសិក្សាបុរាណវិទ្យា ប្រវត្តិសាស្ត្រ រចនាបទសិល្បៈនិងសិលាចារិក យើងក៏បានដឹងការវិវត្តខ្លះៗនៃប្រាសាទអង្គរវត្ត ។ នៅឆ្នាំ១២៩៥ ទូតបរទេសមកពីប្រទេសចិនឈ្មោះជីវតាក្វាន់ បានចូលមកទស្សនកិច្ចនៅទីក្រុងមហានគរព្រមទាំងបានស្នាក់នៅទីនេះអស់រយៈពេលមួយឆ្នាំ ។ លោកជីវតាក្វាន់បានកត់ត្រារឿងរ៉ាវគ្រប់បែបយ៉ាងដែលបានជួបប្រទះនៅពេលនោះ រួចរួបរួមចងក្រងសៀវភៅមួយក្បាលឡើងឈ្មោះ“ ប្រពៃណីនៃស្រុកចេនឡា” ។ ក្នុងសៀវភៅ“កំណត់ហេតុរបស់ជីវតាក្វាន់អំពីប្រពៃណីនៃអ្នកស្រុកចេនឡា”ដែលប្រែនិងរៀបរៀងដោយលោកលី ធាមតេង[1] មានប្រយោគមួយដែលលោកជីវតាក្វាន់សរសេរថា“ចេញពីកំពែងតាមទ្វារខាងត្បូងទៅ ចំងាយប្រមាណជាជាងកន្លះលី តាមពាក្យចចាមអារាមគេនិយាយថាមានចេតិយលូប៉ាន ស្ថិតនៅក្រៅកំពែងខាងត្បូងជាងកន្លះលី ហើយមានបរិវេណព័ទ្ធជុំវិញប្រមាណជាង១០លីនឹងមានបន្ទប់ថ្មជាច្រើនរយទៀតផង” ។ តាមពាក្យសំដីនេះអ្នកប្រាជ្ញសន្និដ្ឋានថាជាប្រាសាទអង្គរវត្ត ។ ចំណែកពាក្យ“លូប៉ាន”តាមភាសាចិនជាឈ្មោះមេជាងសាងប្រាសាទក្នុងរឿងព្រេងចិនបុរាណដូចជាជំនឿរបស់ខ្មែរយើងថា“ ព្រះពិស្ណុការ”ជាអ្នកសាងប្រាសាទអង្គរវត្ត ។ ជីវតាក្វាន់អាចឮខ្មែរយើងហៅប្រាសាទ

---

* បរិញ្ញាប័ត្រទស្សនវិជ្ជា និងកំពុងសិក្សាយកអនុបណ្ឌិតផ្នែកអក្សរសាស្ត្រចុងបូព៌ា

[1] **លី ធាមតេង, “កំណត់ហេតុរបស់ជីវតាក្វាន់ អំពីប្រពៃណីនៃអ្នកស្រុកចេនឡា”, បោះពុម្ពលើកទី៣, ភ្នំពេញ ព.ស.២៥១៦ ⁄ ១៩៧៣**

នេះថា“ចេតិយព្រះពិស្ណុការ”ហើយធ្លាប់ឮរឿងដំណាលតៗគ្នាថា ព្រះពិស្ណុកាគឺជាមេជាងដ៏មានមហិទ្ធិឫទ្ធិជាអ្នកកសាងប្រាសាទអង្គរវត្ត ។ ម្យ៉ាងវិញទៀតប្រាសាទអង្គរវត្ត មិនមែនមានឈ្មោះដូចយើងហៅដូចសព្វថ្ងៃនេះទេ គេហៅថា “ព្រះពិស្ណុលោក”ដែលជាបរមនាមក្រោយពេលទីវង្គតរបស់ព្រះបាទសុរិយវរ្ម័នទី ២ ។ ព្រះអង្គជាស្ថាបនិកប្រាសាទអង្គរវត្ត ។ តាមការស្រាវជ្រាវបញ្ជាក់ថា ព្រះអង្គបានសាងប្រាសាទអង្គរវត្តដើម្បីឧទ្ទិសដល់ព្រះវិស្ណុហើយព្យាយាមសាងបុណ្យសាងកុសលគ្រប់បែបយ៉ាងដើម្បីប្រាថ្នាឧទ្ទិសខ្លួនព្រះអង្គផ្ទាល់រលាយចូលជាតួអង្គព្រះវិស្ណុដើម្បីជួយស្រោចស្រង់សត្វលោកក្រោយពីព្រះអង្គចូលទីវង្គត ។ ដូច្នេះអង្គរវត្តគឺជាចេតិយឬផ្នូរសំរាប់បញ្ចុះព្រះបរមសពរបស់ព្រះបាទសុរយវរ្ម័នទី ២ នៅត្រង់កំពូលកណ្ដាល ហើយប្រជាជនខ្មែរពីសព្វសារទិសរមែងបង្អោនកាយចូលមកសក្ការៈបូជាហើយហៅតៗគ្នាថា“ព្រះបរមពិស្ណុលោកឬចេតិយព្រះវិស្ណុ” តែក្រោយមកអ្នកស្រុកបែរគិតថា ព្រះវិស្ណុកាឬពិស្ណុកាជាមេជាងកសាងប្រាសាទអង្គរវត្តទៅវិញ ។

ក្រោយពីទស្សនកិច្ចនិងរឿងរ៉ាវដែលជាសំដីសំដៅរបស់លោកជីវតាខ្វាន់អំពីប្រាសាទអង្គរវត្តនៅឆ្នាំ១២៩៥មក (ក្រោយពីស្ថាបនាប្រាសាទអង្គរវត្តរយៈពេល១៨៥ឆ្នាំ)យើងបានជួបឯកសារដែលសរសេរជាប់នឹងសសរលើប្រាសាទអង្គរវត្តរបស់អ្នកប៉ាងជាពាក្យកាព្យឈ្មោះ“ល្បើកអង្គរ” សរសេរក្នុងឆ្នាំ១៦២០ ជាសិលាចារឹកខ្មែរក្រោយសម័យមហានគរ ដោយផ្ដើមសេចក្ដីថា

សាស័ព្ទសេដ្ឋោ ឯកបញ្ចទោ
សសោត្តមំ ឆ្នាំវក នក្សត្រ
វិវឌ្ឍន៌ សាធុការំ
តិលកាលា ។
ខ្ញុំវង្សត្រកូល ពូជពង្សត្រកូល
ជាតិវង្សា នាមអ្នកប៉ាង
ដាក់សាងសាស្ត្រា លំនាំនគរា
ច្បាប់ទៅមុខហោង ។

ហើយអធិប្បាយអំពីប្រាសាទអង្គរវត្តនិងអ្នកកសាងថា

ស្រាប់នឹងថ្នាថ្លែង ចចារចែងសរសើរមហា
ប្រាសាទទាំងប្រាំប្រា កដកបកពិចិត្រក្រៃ ។
ប្រាសាទនេះឯងណា ព្រះឥន្ទ្រាទិព្វទេពថ្លៃ
ប្រើព្រះពិស្ណុកានៃ ចុះមកថ្វាយក្សត្រា ។

បានពោលសរសើរសំរសប្រាសាទអង្គរវត្តដោយប្រៀបធៀបទៅនឹងឋានត្រៃត្រឹង្សថា

ប្រាសាទប្រាំបួន រុងរឿងថៃធួន
ឆ្លូវឆ្លាក់ក្រាស់ក្រៃ ភ្ញីវល្លិ៍លោតលាក់
ហាក់ដូចឋានត្រៃ ត្រឹង្សត្រឹមវិស័យ
មុខគួរឧបមា ។

អត្ថបទល្បើកអង្គរនេះជាអក្សរសិល្ប៍ដ៏សំខាន់ក្នុងការសិក្សាអំពីទស្សនគតិខ្លះរបស់ខ្មែរយើងនៅសតវត្សទី១៦អំពីប្រាសាទអង្គរវត្ត មិនតែប៉ុណ្ណោះធ្វើឱ្យយើងយល់ពីការវិវត្តន៍នៃអក្សរសាស្ត្រខ្មែរក្រោយសម័យអង្គរថែមទៀតផង ។

អត្ថបទមួយទៀតដែលគួរឱ្យសិក្សាអំពីកេរ្តិ៍ឈ្មោះអង្គរវត្តគឺ“កាព្យនិរាសអង្គរវត្ត”របស់ឧកញ៉ាសុត្តន្តប្រីជាឥន្ទ សរសេរក្នុងឆ្នាំ១៩២៥ ។ លោកឧកញ៉ាបានធ្វើដំណើរពីខេត្តបាត់ដំបងតាមដងស្ទឹងសង្កែចូលមកបឹងទន្លេសាបហើយឡើងមកតាមច្រកភ្នំក្រោមចូលមកខេត្តសៀមរាបដើម្បីចាត់ពិធីទទួលព្រះរាជដំណើរព្រះបាទស៊ីសុវត្ថិមកធ្វើបុណ្យបំពេញព្រះរាជកុសលនៅប្រាសាទអង្គរវត្ត ដោយផ្តើមថា

និរាសរ័តន៍វត្តនគរសែនវរចិត្ត
កាលចាកចេញឃ្លាតចរសមមិត្ត
កែវជីវ៉ាគួជីវិតភិសម័យ ។
ដោយមានបុណ្យចក្រពង្សវង្សក្សត្រីយ៍
ស៊ីសុវត្ថិកែវហ្វាសុលាលៃ
ព្រះចៅក្រុងកម្ពុជាធិបតី
មានព្រះទ័យចង់ប្រាថ្នាពោធិញាណ ។
ទ្រង់យាងមកអង្គរវត្តសមោសរ
ចាត់បដិសង្ខរទីបុរាណ
បរិច្ចាគរាជទ្រព្យប្រកបទាន
បំពេញញាណសម្តោធិបញ្ញា ។

លោកបានផ្តើមសេចក្តីរៀបរាប់អំពីអង្គរវត្តថា

ខ្ញុំបាទយល់ទីកន្លែងលោកតែងថ្មី
នឹងសរសើរបារមីព្រះចមក្សត្រិយ៍
គ្រាន់តែស្តេចយាងម្តងក៏កើតចាត់
ទីព្រៃស្ងាត់ក្លាយកើតជាវាំងស្ថាន ។

នេះបញ្ជាក់ថាប្រាសាទអង្គរវត្តមិនត្រូវបានគេបោះបង់ចោលក្នុងព្រៃ ក្នុងទីរហោស្ថានរហូតនោះទេ ស្តេចខ្មែរគ្រប់ព្រះអង្គព្រមទាំងនាម៉ឺន មន្ត្រី សេដ្ឋី រមែងធ្វើដំណើរមកសក្ការបូជានិងចាត់ធ្វើបុណ្យឧទ្ទិសកុសលឥតដាច់ ។

ក្នុងកាព្យនិរាសអង្គរ មានរៀបរាប់អំពីក្បូរក្បាច់រចនារបស់ប្រាសាទអង្គរវត្តយ៉ាងលំអិតហើយពោលសរសើរនូវសំរស់អង្គរវត្តថា

ពិតប្រាសាទស្អាតប្រសើរដំណើរប្រាង្គ
ប្រាំកំពូលខ្ពស់បីជាន់រស់រួមគ្នា
ជាន់គ្រឹះគ្រប់ជាន់ជាព័ទ្ធជុំ
ប្រាសាទធំត្រង់កណ្តាលអណ្តែតជាបាច់ចង ។

ដូចគ្នាដែរក្នុងឆ្នាំ១៩២៦ សម្តេចព្រះសង្ឃរាជ ហួត តាត បានព្រះរាជនិពន្ធសៀវភៅ “អំពីប្រាសាទ

ខ្លះនៅទីក្រុងអង្គរ” ។

សេចក្ដីសង្ខេបនៃសៀវភៅនេះ មានការអធិប្បាយអំពីរឿងដំណាល ព្រះវិស្សុកម្មកសាងអង្គរវត្ត ទិដ្ឋភាពទូទៅនៃតួប្រាសាទ និងអធិប្បាយរូបក្បាច់រចនានៅថែវជុំវិញយ៉ាងលំអិត *ជាពិសេសអធិប្បាយរឿងនរកទាំង៣២ជាន់ និងឋានសួគ៌ទាំង៣៧ជាន់* ។

ឯកសារមួយទៀតគឺសៀវភៅ“មគ្គុទេសក៍នគរ”និពន្ធដោយព្រះភិក្ខុបណ្ឌិតប៉ាង ខាត់ ជាសៀវភៅដែលកុលបុត្រកុលធីតាខ្មែរគួររកអានឱ្យបាន ។ ព្រះតេជគុណបានផ្ដើមពាក្យប្រារព្ធថា “*បើគេបានដើរមើលបុរាណស្ថានគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា គេនឹងបានដឹងប្រាកដថា ប្រទេសកម្ពុជាក្នុងអតីតកាលជាប្រទេសរុងរឿងយ៉ាងឯកក្នុងចំណោមប្រទេសដែលស្ថិតនៅទិសអគ្នេយ៍នៃទ្វីបអាស៊ី*” ហើយបានបញ្ចប់នូវពាក្យផ្ដាំផ្ញើរដល់យុវជនខ្មែរទាំងឡាយថា“**កុំមើលថូកទេរត្រូវចស្ងួរថូផង, កុំមើលថូកទេរត្រូវចស្ងួរថូផង, កុំមើលថូកទេរត្រូវចស្ងួរថូផង**” ។

ចំពោះប្រាសាទអង្គរវត្តព្រះតេជគុណបានរៀបរាប់អំពីភាពអស្ចារ្យនិងកេរ្ដិ៍ឈ្មោះល្បីល្បាញថា “នគរវត្តជាប្រាសាទដែលល្អជាងគេក្នុងចំណោមប្រាសាទទាំងឡាយនៅនគរ គេកសាងក្នុងសម័យនៃវិទ្យាសាស្ត្រ (មិនទាន់)កំពុងចំរើនបរិបូណ៌ ព្រោះមានរូបរាងល្អនិងសក្តិសមនៃរូបរាងលេចស្រស់ឡើង កាលណាគេចូលទៅជិតហើយគេអាចយកផ្គូរ(ទូរ)គ្នានិងវិស្វកម្មនៃប្រទេសអស្តង្គតបាន ។ ប្រាសាទនេះមានទំរង់ទ្រង់ទ្រាយនិងលំអដ៏លើសលប់ ដូចជានៅក្នុងរាជវង្សល្វីទី ១៤នៃប្រទេសបារាំងសែស ក្នុងរាជវង្សខ្មែរនេះមានការលេងសួនដំផ្កា រំលេចស្មៅសេះ សណ្ឋានល្អមើលពីចំងាយ និងមាត៌ាធំទូលាយៗ” ។

ការផ្ដើមសេចក្ដីនេះ មានការប្រៀបធៀបទៅនឹងភាពអស្ចារ្យនៃស្ថាបត្យកម្មអឺរ៉ុបបុរាណដូចជា ពីរ៉ាមីត ហើយការលំអប្រាសាទក៏មានលក្ខណៈស្រដៀងគ្នានិងរាជវង្សល្វីទី ១៤ ដូចជាមានការដាំសួនច្បារ ជីកស្រះនិងតុបតែងផ្លូវចូលជាដើម ។

ខាងលើនេះគ្រាន់តែជាទស្សនគតិខ្លះៗរបស់អ្នកប្រាជ្ញខ្មែរចំពោះប្រាសាទអង្គរវត្ត ចំណែកពួកអឺរ៉ុបវិញមានអ្នកប្រាជ្ញ អ្នកនិពន្ធជាច្រើនដែលបានចូលមកសិក្សាស្រាវជ្រាវអំពីប្រាសាទអង្គរវត្តហើយបានសរសេរអួតសរសើរអំពីភាពអស្ចារ្យរបស់គេ ដូចជាអមតវាចារបស់អ្នកប្រវត្តិសាស្ត្រដ៏ល្បីល្បាញជនជាតិអង់គ្លេសឈ្មោះអារ៉ណូលត៍ ថយន៍ប៊ី បានបន្លឺពាក្យខ្លីៗតែធ្វើឱ្យញាប់ញ័របេះដូងដល់ភ្ញៀវទេសចរណ៍ទូទាំងពិភពលោកថា

*“See Angkor Wat and died ”*

**ស្លាប់ក៏មិនស្ដាយបើបាននៅឃើញប្រាសាទអង្គរវត្តផ្ទាល់នឹងភ្នែកម្ដង ក្នុងឆាកជីវិតនេះ**

ក្រោយពីការធ្វើដំណើរចូលមកទស្សនកិច្ចរបស់ទូតចិនឈ្មោះជីវតាខ្វាន់៤០៩ឆ្នាំ គឺប្រហែលក្នុងឆ្នាំ ១៦០៤ អង្គរវត្តត្រូវបានគេស្គាល់ជាលើកដំបូងសំរាប់បណ្ដាប្រទេសអឺរ៉ុប នៅពេលដែលគ្រូបង្រៀនសាសនាគ្រីស្តជនជាតិប៉ទុយកាល់ឈ្មោះ*សានអានតូនីអូ* បានសរសេរអត្ថបទរបស់ខ្លួនទាក់ទងនិងអង្គរវត្តឈ្មោះ “អត្ថបទដែលខ្លីហើយជាសេចក្ដីពិតទាក់ទងហេតុការណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា”ជាអត្ថបទដំបូងដែលសរសេរឡើងដោយពួកអឺរ៉ុបហើយអួតសរសើរអំពីប្រាសាទអង្គរវត្តដោយពណ៌នាថា *ជាប្រាសាទដែលកសាងយ៉ាងអស្ចារ្យ ហើយជាប្រាសាទដែលកសាងឡើងដោយជនជាតិរ៉ូម៉ាំង* ។

នេះជាពាក្យដែលគួរអោយចង់សើច ដែលទស្សនគតិរបស់ពួកអឺរ៉ុបរមែងអួតសរសើរខ្លួនឯងហើយថាគេមិន

ដល់ខ្លួន ជាពិសេសក្រុមប្រទេសអាស៊ីឬក្នុងប្រទេសខ្មែរយើងតែម្តង....ឬនេះគ្រាន់តែជាទស្សនៈធម្មតាៗរបស់ម្ចាស់អាណានិគមទាំងឡាយនៅលើពិភពលោកយើងនេះ ?

កន្លងមកទៀតបាន៧៤ឆ្នាំគឺក្នុងឆ្នាំ១៦៧៨ក៏មានអ្នកបង្រៀនសាសនាគ្រឹស្តជនជាតិបារាំងឈ្មោះ"*ផើវេរយ៍*"បានសរសេរអត្ថបទអំពីបុរាណស្ថានខ្មែរដោយហៅឈ្មោះថា"អង្គរ"ឬ "Onco" ដោយអធិប្បាយថា *ប្រាសាទនេះជាសង្វេជនីយស្ថានជាទីគោរពសក្ការបូជារបស់អ្នកស្រុកនេះ ដូចគ្នានិងសាសនិកជននិកាយរ៉ូម៉ាំងកាតូលិកគោរពព្រះវិហារសេនពីទ័រនៅឯក្រុងរ៉ូមដូច្នេះដែរ* ។

នេះសបញ្ជាក់ថា ភាពសក្តិសិទ្ធនៃមហាប្រាសាទអង្គរវត្តត្រូវបានប្រជាជនខ្មែរយើងគោរពបូជាតាំងតែសម័យដែលទើបនឹងកសាងរួចថ្មីៗដរាបតរៀងមក ។

នៅឆ្នាំ ១៦៧៥ក៏មានការបោះពុម្ពផ្សាយនៅទីក្រុងម៉ាទ្រិចប្រទេសអេស្ប៉ាញ៉ុល ដោយអធិប្បាយដល់ភាពអស្ចារ្យនៃប្រាសាទអង្គរតូច អង្គរធំរបស់ខ្មែរយើង ហើយសរសេរថា *អាចជាថ្មីដែការកសាងរបស់ជនជាតិយិវ ជនជាតិរ៉ូម៉ាំង ឬព្រះបាទអាឡិចសង្គ្រាមហារាជ* ។

រហូតដល់ឆ្នាំ ១៨១៥ទើបមានការបកប្រែកំណត់ហេតុរបស់ជីវតាខ្វាន់ជាភាសាបារាំង អង់គ្លេស ផ្សព្វផ្សាយទូទាំងទ្វីបអឺរ៉ុប ធ្វើឱ្យមានអ្នកឯកទេសខាងប្រវត្តិសាស្ត្រ បុរាណវត្ថុវិទ្យាចាប់អារម្មណ៍ចូលមកសិក្សាស្រាវជ្រាវកាន់តែខ្លាំងឡើង ។

ដល់ឆ្នាំ១៨៦០ លោក*អង់រីមូហោ* ជាអ្នកប្រាជ្ញ ជាអ្នកធម្មជាតិវិទ្យា ជនជាតិបារាំងបានធ្វើដំណើរមកកាន់ប្រទេសសៀម ប្រទេសកម្ពុជានិងប្រទេសឡាវរវាងឆ្នាំ<u>១៨៥៨-១៨៦០</u>ទីបំផុតអង់រី មូហោ បានចោលជីវិតនៅប្រទេសឡាវដោយជំងឺគ្រុនចាញ់ ។ អង់រី មូហោត្រូវបានគេទទួលស្គាល់ថាជាអ្នករកឃើញប្រាសាទអង្គរវត្តនិងប្រាសាទបុរាណខ្មែរមួយចំនួនទៀត តាមការពិតការនិយាយដូច្នេះជាការមិនត្រឹមត្រូវទាល់តែសោះ ព្រោះប្រាសាទអង្គរវត្តមិនដែលបាត់បង់ទៅណាហើយមិនដែលបាត់បង់នៅក្នុងព្រៃរហោស្ថាននោះទេ គ្រាន់តែស្តេចខ្មែរជំនាន់ក្រោយផ្លាស់រាជធានីពីទីក្រុងមហានគរទៅតាំងនៅចតុមុខ លង្វែក ឧត្តុង្គ និងភ្នំពេញ តែព្រះមហាក្សត្រខ្មែរគ្រប់ព្រះអង្គនិងប្រជាជនខ្មែរព្រមទាំងជនបរទេសធ្វើដំណើរមកគោរពសក្ការបូជាប្រាសាទអង្គរវត្តឥតដាច់ ព្រមទាំងមានការជួសជុលខ្លះទៀតផង ។

អត្ថបទស្តីពីប្រាសាទអង្គរវត្តរបស់អង់រី មូហោបានបើកទំព័រសករាជថ្មីឱ្យពួកបញ្ចឹមប្រទេសបានឃើញប្រាសាទបុរាណខ្មែរជារូបធម៌ឡើង ។ នៅក្នុងសៀវភៅការធ្វើដំណើរឆ្លងកាត់សៀម កម្ពុជា ឡាវនិងអាណាម អង់រី មូហោបានពោលអួតសរសើរអំពីភាពអស្ចារ្យរបស់ប្រាសាទអង្គរវត្តថា :

> ប្រាសាទមួយក្នុងបណ្តាប្រាសាទទាំងឡាយនេះអាចចាត់ទុកថាជាគូប្រកួតប្រជែងក្នុងបណ្តាប្រាសាទដែលសាងដោយស្តេច**សូឡូម៉ង់**អ្នកមានមហិទ្ធិរិទ្ធ វត្ថុកសាងទាំងនេះបានស្ថាបនាដោយ**មិឆែល អង់គេលឡូ**ក្នុងសម័យបុរាណហើយគួរតែត្រូវបានលើកតំកើងជាវត្ថុប្រកបដោយកិត្តិយសអស្ចារ្យក្នុងចំណោមវិហារទាំងឡាយរបស់យើង ។ វាធំធេងអស្ចារ្យជាងបណ្តាពីរ៉ាមីតទាំងឡាយដែលបន្សល់ទុកអោយយើងដោយពួកក្រិចឬពួករ៉ូម៉ាំង ហើយវាផ្ទុយស្រលះពីរដ្ឋរបស់ពួកអនារិយជនដែលឥឡូវនេះប្រទេសរបស់គេត្រូវបានដួលរំលំ ។

ក្រោយពីការបោះពុម្ពផ្សាយពីកាធ្វើដំណើរផ្សងព្រេងរបស់អង់រី មូហោ ត្រឹម៣ឆ្នាំ បារាំងក៏ចូលមកត្រួតត្រាទឹកដីខ្មែរជាប្រទេសអាណានិគម ព្រមទាំងមានការបញ្ជូនអ្នកជំនាញការផ្នែកបុរាណវិទ្យាមកសិក្សាស្រាវជ្រាវអំពីប្រាសាទបុរាណខ្មែរជាបន្តបន្ទាប់ដូចជា ***ចច ខមម៉ៃ, អេទៀនអ៊ៃម៉ុងតិយេ, អង់រី ម៉ាឆាល, លុយស៍ ហ្វីណូត៍, ចច សេដេស, ប៉ូល ប៉េលលិអូត៍, វិគតរ គោលូបេហ្វ*** ....ជាដើម ។

អង្គរវត្តគឺជាពីរ៉ាមីតនៃទ្វីបអាស៊ី ជាសម្បត្តិវប្បធម៌ដ៏មានដំលៃរបស់ខ្មែរយើង ហើយអង្គរវត្តនេះឯងក្លាយទៅជានិមិត្តរូបសាមគ្គីភាពដ៏រឹងមាំរបស់ប្រជានុរាស្ត្រខ្មែរយើង ។

នាបច្ចុប្បន្នមានកវី អ្នកនិពន្ធខ្មែរជាច្រើនបានសរសេររៀបរាប់ពីភាពអស្ចារ្យនិងមហិទ្ធិរិទ្ធរបស់ប្រាសាទអង្គរវត្ត ដូចដែលលោកគង់ ប៊ុនឈឿន ដែលជាអ្នកសរសេររឿងប្រឡោមលោកខ្មែរដ៏ល្បីល្បាញ បានសរសេរជាបទកំណាព្យថា* :

អង្គរថ្កុំថ្កើង ដោយសារខ្មែរយើង ចេះសាងវប្បធម៌
រូបរួមសាមគ្គី មូលមីរអេបអរ ព្រលឹងវប្បធម៌
រឹងមាំមួនខ្លាំង ។
ខ្មែរល្បីពេលនោះ មិនមែនដោយឈ្លោះ មិនមែនដោយច្បាំង
មិនមែនអាងទ័ព គ្រាប់រាប់រយឃ្លាំង ឈ្នះដោយកំលាំង
ឈ្នះមិនយូរទេ ។

តាមទស្សនាវដ្តីថាម(time magazine)បានសរុបរឿងសិល្បៈកម្មប្រាសាទបុរាណក្នុងឱកាសសហស្សវត្សថ្មីរបស់ពិភពលោកថា រយៈវេលាដែលអាណាចក្រខ្មែរមានការកសាងប្រាសាទអង្គរវត្ត គឺក្រោយការកសាង*មហាវិហារសានមារ៉ុក*កណ្តាលកោះ*វេនិស*កន្លងទៅបាន២០០ឆ្នាំ ទើបមានការកសាងមហាប្រាសាទព្រះវិស្ណុលោកឬប្រាសាទអង្គរវត្តនៅដើមសតវត្សទី១២(១១១៣-១១៥០)កសាងមុន*វិហារណោត្រដាម* រចនាបទបែបអធិកយុគដំបូងរបស់ក្រុងប៉ារីស និងមុនការធ្វើដំណើររបស់*ម៉ាកូ ប៉ូឡូ* (ក្នុងឆ្នាំ១២៩៥) មុនការរកឃើញទ្វីបថ្មីរបស់*គ្រិស្តូហ្វើរ ខូឡាំប៊ស*(ក្នុងឆ្នាំ ១៤៩២) និងមុនវិហារសក្ខីស្នេហ៍*ថាច់ម៉ាហាល់*នៃក្រុង*អគ្រា* ប្រទេសឥណ្ឌាដល់ទៅ៥០០ឆ្នាំ ។

ចំណែកពត៌មានដែលចេញពីនេសិនណែលជីអូក្រាហ្វិក(National Geographic)រៀបរាប់អំពីភាពអស្ចារ្យនៃប្រាសាទអង្គរវត្តថា ក្នុងខណៈដែលជាងខ្មែររាប់សែននាក់កំពុងឆ្លាក់ថ្មភ្នំកសាងសិល្បកម្មដ៏ធំស្កឹមស្កៃគឺអង្គរវត្តនោះ មហានគរឡុងដុងស្ថិតក្រោមសភាពជាភូមិអ្នកស្រុកតូចៗដែលមានប្រជាជនត្រឹមតែ២ម៉ឺននាក់ប៉ុណ្ណោះ ។

ឆ្លងកាត់យុគសម័យនៃសេចក្តីរុងរឿង រមែងនាំទៅរកភាពរុះរោយ ហើយភាពរុះរោយក៏ជាកំលាំងចលករនាំទៅរកភាពរុងរឿងដែរ ។ តាមច្បាប់បដិច្ចសមុប្បាទ វត្ថុធាតុគ្រប់យ៉ាងនៅលើសកលលោកយើងនេះ រមែងកើតឡើងហើយ តាំងនៅមួយរយៈ ហើយរលត់បាត់ទៅនៅទីបញ្ចប់ ។ ដូចគ្នាដែរ ភាពធ្លាក់ចុះនៃភាពរុងរឿងសម័យមហានគរបានកើតឡើង ហើយបន្តមកអស់រយៈពេលមួយសហស្សវត្សន៏ ភាពធ្លាក់ចុះនេះនឹងបាត់រលត់ទៅវិញជាក់ជាមិនខានបើខ្មែរគ្រប់រូបមានភាពសាមគ្គីគ្នា មានប្រាសាទកំពូលប្រាំជាស្នូលកណ្តាល

* កម្ពុជសុរិយា, ឆ្នាំទី៥៣ លេខ៤ ខែតុលា-វិច្ឆិកា-ធ្នូ ព.ស.២៥៤៣ គ.ស.១៩៩៩, ទំព័រ ៧៧, ល្បះទី១-២

ទង់បក់រវិចៗពញ្ញាក់ស្មារតីអោយយើងមានសុឆន្ទៈម៉ឺងម៉ាត់ រឹងប៉ឹង ឈរលើសតិបញ្ញា ប្រកបដោយហេតុផល មានមនសិកា ប្រកបដោយទេពកោសលខ្ពស់។ *អង្គរវត្តមិនមែនគ្រាន់តែជាអច្ឆរិយវត្ថុពិភពលោកប៉ុណ្ណោះទេ ឬគ្រាន់តែជានិមិត្តរូបដ៏អស្ចារ្យខាងស្ថាបត្យកម្មក៏មិនមែនដែរ តែអង្គរវត្តគឺជាក្តីសង្ឃឹមរបស់ប្រជានុរាស្ត្រខ្មែរទាំងអស់* ។

ដូចដែលមានអ្នកកាសែត អ្នកទស្សនាវដ្ដីបានសរសេររៀបរាប់ពិតំលៃពិត ប្រាកកដនៃ ប្រាសាទអង្គរវត្ត សំរាប់ប្រជាជាតិខ្មែរថា :

*"To the Khmer people, Angkor Wat is more than just an ancient pile of stones, it is more than just the remains of a highly advanced kingdom, it is more than just a tourist attraction - to the Khmers it is a symbol of hope."*

ដែលប្រែថា " សំរាប់ប្រជាជនខ្មែរ ប្រាសាទអង្គរវត្តមិនមែនគ្រាន់តែជាគំនរថ្មភក់បុរាណ មិនមែនគ្រាន់តែជាអាណាចក្រដ៏ចំរើនរុងរឿងដែលនៅសេសសល់លើសកលលោកយើងនេះ ឬមិនមែនគ្រាន់តែជាតំបន់ទេសចរណ៍ដ៏មានប្រជាប្រិយប៉ុណ្ណោះទេ តែអង្គរវត្តគឺជានិមិត្តរូបតែមួយគត់នៃក្តីសង្ឃឹមរបស់ប្រជាជនខ្មែរ"

## ឯកសារយោង


- អាចារ្យប៉ាង ខាត់, មគ្គុទេសក៏នគរ ភាគ១-២, ពុទ្ធសាសនបណ្ឌិត, ភ្នំពេញ: ព.ស.២៥០០
- ឡី ធាមតេង, កំណត់ហេតុរបស់ជិវតាខ្វាន់អំពីប្រពៃណីនៃអ្នកស្រុកចេនឡា, បោះពុម្ពលើកទី៣, ភ្នំពេញ: ព.ស.២៥១៦/១៩៧៣
- ឧកញ៉ាសុត្តន្តប្រីជាឥន្ទ, និរាសអង្គរវត្ត, ពុទ្ធសាសនបណ្ឌិត, ភ្នំពេញ: ព.ស.២៥៤១/១៩៩៧
- សាន្តិ ភក្តីខាំ-សុចិត្ត វង្សទេស, អង្គរវត្ត ទស្សនះខ្មែរ, បាងកក: កញ្ញា ព.ស.២៥៤៦ (ភាសាសៀម)
- ពិស្ណុ សុភ., តាមក្លិននាងអប្សរា តាមរកនគរវត្ត-នគរធំ, បាងកក: តុលា ព.ស.២៥៤៦ (ភាសាសៀម)
- Henri Mouhot. Travels in Siam, Cambodia, Laos and Annam. White Lotus Press, Bangkok 2000